# សេចក្តីថ្លែងហេតុ

# នៃសេចក្តីព្រាងច្បាប់ ស្តីពី

# “ក្រមព្រហ្មទណ្ឌ”

# ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៩

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់ ស្តីពី "ក្រមព្រហ្មទណ្ឌ"

ក្រមព្រហ្មទណ្ឌ គឺជាបណ្តុំនៃរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ក្នុងនោះ បទប្បញ្ញត្តិមួយផ្នែកចែងអំពីគោលការណ៍គ្រឹះ និង វិធានរួមនៅក្នុងនីតិព្រហ្មទណ្ឌសម្រាប់ចៅក្រមយកទៅអនុវត្តក្នុងការផ្តល់យុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមួយផ្នែកទៀត ចែងអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោស។ ក្រមព្រហ្មទណ្ឌ គឺជាប្រភេទច្បាប់សារធាតុរួមមួយ ដែលមានចរិតនិងគោលដៅខុសពីក្រមរដ្ឋប្បវេណី ។ ក្រមរដ្ឋប្បវេណីមានចរិតនិងគោលដៅគ្រប់គ្រងលើទំនាក់ទំនាក់ផ្នែករដ្ឋប្បវេណីរវាងបុគ្គលឯកជន និងបុគ្គលឯកជន ជាអាទិ៍ ទំនាក់ទំនងកិច្ចសន្យា ទំនាក់ទំនងអាពាហ៍ពិពាហ៍និងគ្រួសារ និងទំនាក់ទំនងទ្រព្យសម្បត្តិ ជាដើម។ ចំណែកឯក្រមព្រហ្មទណ្ឌវិញ មានចរិតនិងគោលដៅចម្បងបម្រើឱ្យប្រយោជន៍សាធារណៈ តាមរយៈការធានារក្សាការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សិទ្ធិសេរីភាពបុគ្គល សេចក្តីថ្លៃថ្នូរ និងភាពសុខសាន្តជូនប្រជាជន។ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា មានក្រមធំៗចំនួន ៣ គឺ : ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ដែលត្រូវបានស្ថាប័ននីតិប្បញ្ញត្តិអនុម័ត ហើយត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើរួចរាល់ជាស្ថាពរ នៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភាកន្លងទៅ ។ ដោយឡែក ក្រមព្រហ្មទណ្ឌពុំទាន់ត្រូវបានអនុម័តនៅឡើយទេ។ បទប្បញ្ញត្តិព្រហ្មទណ្ឌដែលមានជាធរមានបច្ចុប្បន្ន ភាគច្រើនមានលក្ខណៈស្ថិតនៅរាយប៉ាយនៅក្នុងអត្ថបទគតិយុត្តខុសៗគ្នា ដែលធ្វើឱ្យមានការលំបាកនៅក្នុងការយកទៅប្រើប្រាស់ និងស្វែងយល់ឱ្យបានពេញលេញនៅក្នុងវិស័យមួយនេះ ។ ម្យ៉ាងទៀត បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនេះ នៅមានចន្លោះខ្វះខាតជាច្រើន ដែលធ្វើឱ្យប្រព័ន្ធបង្ក្រាបបច្ចុប្បន្ន ជួបប្រទះនូវការលំបាក និងឧបសគ្គ ដើម្បីប្រយុទ្ធប្រឆាំងប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ទៅនឹងទម្រង់ថ្មីនៃបទល្មើសក្នុងសង្គម និងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ ក្នុងគោលដៅធានារក្សាការពារឱ្យបាននូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាជន។ ទន្ទឹមនឹងនេះ គោលការណ៍គ្រឹះធំៗនៅក្នុងនីតិព្រហ្មទណ្ឌ ដែលជាវិធានរួមសម្រាប់ចៅក្រមយកទៅប្រើប្រាស់នៅក្នុងការផ្តល់យុត្តិធម៌ព្រហ្មទណ្ឌ ក៏មិនទាន់មានចែងកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ននៅឡើយ ដូចជាគោលការណ៍ទាក់ទងនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសព្រហ្មទណ្ឌ ជាដើម។

ដោយមើលឃើញអំពីសារសំខាន់នៃក្រមព្រហ្មទណ្ឌ និងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខ ក្នុងការប្រយុទ្ធប្រឆាំងនឹងទម្រង់ថ្មីនៃបទល្មើស ព្រមទាំងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ ប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងគោលដៅធានាការពារឱ្យបាននូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជន រាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ និងបានចាត់ទុកការជំរុញអនុម័តក្រមព្រហ្មទណ្ឌ គឺជារបៀបវារៈអាទិភាពមួយនៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ខ្លួន ។ រាជរដ្ឋាភិបាល តាមរយៈក្រសួងយុត្តិធម៌ ក៏បានស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពី "ក្រមព្រហ្មទណ្ឌ" នេះឡើង ។ នៅក្នុងឆ្នាំ ២០០១ សេចក្តីព្រាងក្រមព្រហ្មទណ្ឌដើមដំបូង ជាភាសាខ្មែរ ត្រូវបានរៀបចំឡើង និងត្រូវបានប្រគល់ជូនដល់ក្រសួងយុត្តិធម៌ ដើម្បីធ្វើការពិនិត្យ និងកែសម្រួលបន្ថែម ដើម្បីឱ្យក្រមព្រហ្មទណ្ឌនេះ មានលក្ខណៈសមស្រប និងអាចយកមកអនុវត្តបាន នៅក្នុងសង្គមកម្ពុជា ធានាបាននូវប្រសិទ្ធភាព និងមានសង្គតិភាព ភាពរលូន និងស៊ីចង្វាក់គ្នាជាមួយនឹងប្រពៃណីច្បាប់កម្ពុជា និងបទដ្ឋានគតិយុត្តដែលមានស្រាប់នាពេលបច្ចុប្បន្ន ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានតាក់តែងឡើងដោយគិតគូរពិចារណាទៅលើមូលដ្ឋាន ៣ ធំៗ គឺ : ប្រពៃណីច្បាប់ព្រហ្មទណ្ឌកម្ពុជា បទប្បញ្ញត្តិព្រហ្មទណ្ឌដែលមានស្រាប់ និងបរិបទថ្មីៗដែលកំពុងប្រឈម។ ឈរលើមូលដ្ឋាននេះ ក្រមព្រហ្មទណ្ឌត្រូវបានបង្កើតឡើង ដោយគិតគូរអំពីគោលការណ៍ចម្បងៗពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលទៅនឹងនីតិព្រហ្មទណ្ឌ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងបណ្តាបទដ្ឋានអន្តរជាតិនានាដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ និងបានផ្តល់សច្ចាប័ន ។ ដើម្បីធានាសង្គតិភាព ភាពរលូន និងនិរន្តរភាពរវាងច្បាប់ព្រហ្មទណ្ឌចាស់ និងច្បាប់ព្រហ្មទណ្ឌថ្មី ក្រមនេះក៏ត្រូវបានតាក់តែងដោយគោរពគោលគំនិតសំខាន់ៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់ និងក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាឡឺម៉ង់ ដែលជាប្រពៃណីនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ។ ម្យ៉ាងទៀត ដើម្បីបំពេញបន្ថែមចន្លោះខ្វះខាតនៃច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដទៃទៀតដែលមានជាធរមាននាពេលបច្ចុប្បន្ន ក្រមព្រហ្មទណ្ឌក៏បានចែងកំណត់បទល្មើសបន្ថែមផ្សេងទៀតដែលចាំបាច់ ដើម្បីអនុញ្ញាតឱ្យប្រព័ន្ធបង្ក្រាបអាចប្រយុទ្ធប្រឆាំងប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ទៅនឹងទម្រង់ថ្មីៗនៃបទល្មើសក្នុងសង្គម និងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ ក្នុងគោលដៅដើម្បីធានាការពារឱ្យបាននូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជន ។ ទន្ទឹមនឹងនេះ ដើម្បីអាចដោះស្រាយបញ្ហា និងការលំបាកនានាដែលកើតមានឡើងនាពេលបច្ចុប្បន្ន ក្រមព្រហ្មទណ្ឌនេះ ក៏បានបង្កើតឱ្យមានឡើងវិញនូវគោលការណ៍គ្រឹះ និងវិធានរួមនៅក្នុងនីតិព្រហ្មទណ្ឌ ដោយយោងតាមគោលការណ៍ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់របស់កម្ពុជា និងនៅក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាឡឺម៉ង់ និងគោលការណ៍ជាសាកលដទៃទៀតដែលទទួលស្គាល់ជាអន្តរជាតិ ។ ម្យ៉ាងវិញទៀត ដើម្បីធានាឱ្យមានសង្គតិភាព និងភាពរលូន រវាងក្រមព្រហ្មទណ្ឌជាមួយនឹងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀតដែលត្រូវបានស្ថាប័ននីតិប្បញ្ញត្តិអនុម័ត និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើចាប់តាំងពីឆ្នាំ ១៩៩៣ រហូតមក ហើយដែលកំពុងនៅ ជាធរមាននាពេល

បច្ចុប្បន្ន ក្រមព្រហ្មទណ្ឌក៏បានជ្រើសរើស និងកំណត់យករូមមន្តចាំបាច់មួយចំនួនដែលមានចែងនៅក្នុងអន្តរប្បញ្ញត្តិ និងអវសានប្បញ្ញត្តិ ដើម្បីធ្វើការសម្របសម្រួលរវាងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកទាំងនេះ ជាមួយនឹងក្រមព្រហ្មទណ្ឌ នៅក្រោយពេលដែលក្រមនេះ ចូលជាធរមាន ។

ដោយសារក្រមព្រហ្មទណ្ឌ ជាអត្ថបទច្បាប់មួយដែលប្រមូលផ្តុំនូវរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌ ដោយមានការរៀបចំបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ធានាបាននូវសង្គតិភាព ភាពរលូន និងស៊ីចង្វាក់គ្នា ព្រមទាំងបំពេញបន្ថែមនូវអ្វីដែលខ្វះចន្លោះ បានធ្វើឱ្យក្រមនេះ ក្លាយជាឧបករណ៍គតិយុត្តមួយដ៏មានសារសំខាន់ ដែលមិនត្រឹមតែជួយឱ្យចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តផ្សេងទៀត មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងស្វែងយល់ឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយនៅក្នុងវិស័យព្រហ្មទណ្ឌប៉ុណ្ណោះទេ ថែមទាំងអាចជួយអនុញ្ញាតឱ្យប្រជាជនយល់ដឹងរឹតតែច្បាស់អំពីសិទ្ធិ និងព្រំដែននៃការអនុវត្តសិទ្ធិរបស់ខ្លួន ជាពិសេស យល់ដឹងអំពីអំពើដែលត្រូវបានហាមឃាត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ ។

សេចក្តីព្រាងច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" នេះ មាន ៦៧២ មាត្រា ចែកចេញជា ៦ គន្ថី ១២ មាតិកា និង ៥០ ជំពូក ។

**គន្ថីទី ១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ១៨២ មាត្រា ចែកចេញជា ៣ មាតិកា និង ១៤ ជំពូក ។** គន្ថីនេះចែងអំពីគោលការណ៍ទូទៅទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃទោស ។ គន្ថីនេះបានបង្កើតឱ្យមានឡើងវិញនូវគោលការណ៍គ្រឹះធំៗ ជាអាទិ៍ ដូចជា : គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោស គោលការណ៍ទាក់ទងនឹងការបកស្រាយច្បាប់ព្រហ្មទណ្ឌ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ចេតនាប្រព្រឹត្តបទល្មើស គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍ទាក់ទងនឹងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ទន្ទឹមនឹងនេះ គន្ថីទី ១ នេះ ក៏បានបង្កើតឱ្យមានរបបគតិយុត្តមួយច្បាស់លាស់ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ។ម្យ៉ាងវិញទៀត គោលការណ៍ទាក់ទងនឹងទោសព្រហ្មទណ្ឌ ក៏ត្រូវបានចងក្រងបង្កើតបានរបបគតិយុត្តមួយច្បាស់លាស់ ដែលអាចអនុញ្ញាតឱ្យចៅក្រម យកទៅអនុវត្តបានសមស្របតាមកាលទេសៈ និងស្ថានភាពជាក់ស្តែងដើម្បីជាប្រយោជន៍ ដល់សង្គមជាតិទាំងមូល ។

**គន្ថីទី ២ ស្តីពី បទល្មើសប្រឆាំងនឹងបុគ្គល មាន ១៧០ មាត្រា ចែកចេញជា ៣ មាតិកា និង ១៥ ជំពូក ។** គន្ថីនេះ ចែងអំពី បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម បណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់មនុស្ស និងបណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់អនីតិជន និងគ្រួសារ ។ បណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់មនុស្ស រួមមានបទល្មើសសំខាន់ៗ ជាអាទិ៍ ដូចតទៅ : បទឃាតកម្ម បទឃាតកម្មគិតទុកជាមុន បទមនុស្សឃាតដោយអចេតនា បទទារុណកម្មនិងអំពើឃោរឃៅ បទហិង្សាដោយចេតនា បទគំរាមកំហែង បទគំរាមកំហែងថានឹងសម្លាប់ បទបង្កឱ្យមានរបួសដោយអចេតនា បទរំលោភសេពសន្ថវៈ បទប្រទូសគេរខ្មាស បទបង្ហាញគេរភេទ បទរុកគួនខាងផ្លូវភេទ បទចាប់ ឃុំឃាំងនិងបង្ខាំងមនុស្សដោយខុសច្បាប់

បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន បទប៉ះពាល់ដល់បូរណភាពនៃសាកសព បទប្រមាថទីបញ្ចុះសព បណ្តុំនៃបទល្មើសទាក់ទងនឹងការរើសអើង បណ្តុំនៃបទល្មើសទាក់ទងនឹងអំពើពុករលួយនៃនិយោជិតនិងអភិបាល បណ្តុំនៃបទល្មើសទាក់ទងនឹងសញ្ញារកម្ម បទស្រវឹងជាក់ស្តែង បទហៅអ្នកដទៃនៅទីសាធារណៈ បទរំលោភលើលំនៅឋាន បទស្តាប់ឬថតពាក្យសំដីឯកជន បទប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល បទបរិហារកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថជាសាធារណៈ បទប្តឹងបរិហារបង្កាច់កេរ្តិ៍ បទប៉ះពាល់ដល់អាថិកំបាំងខាងវិជ្ជាជីវៈ បទប៉ះពាល់ដល់ការឆ្លើយឆ្លងតាមលិខិត និងបទប៉ះពាល់ដល់ការសម្ងាត់នៃការសន្ទនាតាមទូរស័ព្ទ ។ ចំណែកឯបណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់អនីតិជន និងគ្រួសារ រួមមានបទល្មើសសំខាន់ៗ ជាអាទិ៍ ដូចតទៅ : បទបោះបង់អនីតិជន បទបោះបង់គ្រួសារ បទមិនព្រមប្រគល់អនីតិជន បទដកយកអនីតិជន បទញុះញង់ឱ្យបោះបង់ទារក បទអន្តរការរវាងអ្នកសុំកូននិងអ្នកបោះបង់កូន បទអន្តរការរវាងអ្នកសុំកូននិងស្ត្រីពពោះ បទជំនួស ក្លែង ឬលាក់បំបាំងទារក បទបង្អត់អាហារ ឬគ្មានការថែទាំអនីតិជនអាយុតិចជាង ១៥ ឆ្នាំ បទដាក់អនីតិជនស្ថិតក្នុងលក្ខខណ្ឌការងារដែលបណ្តាលឱ្យខូចសុខភាព បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ បទញុះញង់អនីតិជនឱ្យបរិភោគគ្រឿងស្រវឹង បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈិម បទរៀបចំបង្ហាញភេទឬទំនាក់ទំនងខាងផ្លូវភេទដោយមានការចូលរួមរបស់អនីតិជន បទរំលោភលើអំណាចមេបា បទទ្វេពន្ធភាព បទរួមភេទជាមួយអនីតិជនដោយបុព្វញាតិ និងបទរួមភេទរវាងញាតិលោហិតឬញាតិពន្ធ ។

**គន្ថីទី ៣ ស្តីពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ មាន ៨០ មាត្រា ចែកចេញជា ២ មាតិកា និង ៦ ជំពូក ។** គន្ថីនេះ ចែងអំពីបណ្តុំនៃបទល្មើសទាក់ទងនឹងការយកកម្មសិទ្ធិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត និងបណ្តុំនៃបទល្មើសដទៃទៀតដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ ។ បទល្មើសសំខាន់ៗនៅក្នុងគន្ថីនេះ រួមមាន ជាអាទិ៍ ដូចតទៅ : បទលួច បទកំហែងយក បទគំរាមកំហែងហែកកេរ្តិ៍ បទឆបោក បទរំលោភលើភាពល្ងង់ខ្លៅឬភាពទន់ខ្សោយរបស់អ្នកដទៃ បទបន្លំ បទដេញថ្លៃមិនត្រឹមត្រូវ បទធ្វើជាឧបសគ្គដល់សេរីភាពនៃការលក់ដេញថ្លៃ បទរំលោភលើទំនុកចិត្ត បទបង្វែរវត្ថុរឹបអូសឬដាក់ធានា បទទទួលផលចោរកម្ម បទសំអាតប្រាក់ បទធ្វើឱ្យខូចខាតដោយចេតនា បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត ព្រមទាំងបណ្តុំនៃបទល្មើសនៅក្នុងវិស័យព័ត៌មានវិទ្យា។

**គន្ថីទី ៤ ស្តីពីបទល្មើសប្រឆាំងនឹងជាតិ មាន ២៣៩ មាត្រា ចែកចេញជា ៤ មាតិកា និង ១៣ ជំពូក។** គន្ថីនេះ ចែងអំពីបណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ បណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់វិស័យយុត្តិធម៌ បណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាល និងបណ្តុំនៃបទល្មើសដែលប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ។ បទល្មើសសំខាន់ៗនៅក្នុងគន្ថីនេះ រួមមាន ជាអាទិ៍ ដូចតទៅ : បទរាជឃាតកម្ម បទធ្វើទារុណកម្មឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ បទហិង្សាចំពោះអង្គព្រះមហាក្សត្រ បណ្តុំនៃបទល្មើសក្បត់ជាតិនិងចារកម្ម បទឧបឃាត បទរួមគំនិតក្បត់ បទកុបកម្ម បទដណ្តើមយកអំណាចបញ្ជាយោធា បទរក្សាទុកដោយខុសច្បាប់នូវអំណាចបញ្ជាយោធា បទបង្កើតដោយខុសច្បាប់នូវកងកម្លាំងប្រដាប់អាវុធ បទញុះញង់ឱ្យ

ប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែកទៀត បណ្តុំនៃបទល្មើសប៉ះពាល់ដល់សន្តិសុខនៃកងយោធពលខេមរភូមិន្ទ បណ្តុំនៃបទល្មើសប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ បណ្តុំនៃបទល្មើសប៉ះពាល់ដល់សន្តិសុខសាធារណៈ បណ្តុំនៃបទល្មើសប៉ះពាល់ដល់អាជ្ញាធររបស់រដ្ឋ បណ្តុំនៃបទល្មើសប៉ះពាល់ដល់សាសនារបស់រដ្ឋ បទល្មើសទាក់ទងនឹងអំពើពុករលួយនៃចៅក្រម បណ្តុំនៃបទល្មើសប៉ះពាល់ដល់សេចក្តីសម្រេច និងសកម្មភាពរបស់តុលាការ បណ្តុំនៃបទល្មើសទាក់ទងដល់ការឃុំឃាំង បណ្តុំនៃបទល្មើសប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាល (ដែលក្នុងនោះរួមមានទាំងបណ្តុំនៃបទល្មើសទាក់ទងនឹងអំពើពុករលួយ) ព្រមទាំងបណ្តុំនៃបទល្មើសប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ ដែលក្នុងនោះរួមមាន ដូចជា បណ្តុំនៃបទល្មើសទាក់ទងនឹងការក្លែងបន្លំឯកសារ ការក្លែងបន្លំរូបិយវត្ថុ និងរូបិយបណ្ណ ការក្លែងមូលបត្ររដ្ឋនិងតែមប្រៃសណីយ៍ និងការក្លែងបន្លំសញ្ញាសម្គាល់របស់អាជ្ញាធរ ។

**គន្ថីទី ៥ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ ជំពូក និង ៣ មាត្រា ។** គន្ថីនេះ ចែងអំពីការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក ការអនុវត្តក្នុងពេលវេលានូវវិធានស្តីពីអាជ្ញាយុកាលនៃទោស និងការពន្យាតការអនុវត្តគន្ថីទី ១ ស្តីពីបទប្បញ្ញត្តិទូទៅ ចំពោះច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក ។

**គន្ថីទី ៦ ស្តីពីអវសានប្បញ្ញត្តិ មាន ១ ជំពូក និង ២ មាត្រា ។** គន្ថីនេះ ចែងអំពីការបាត់បង់អានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនមួយចំនួន ព្រមទាំងការអនុវត្តភ្លាមនៃបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ និងការអនុវត្តបទប្បញ្ញត្តិដទៃទៀតនៃក្រមព្រហ្មទណ្ឌក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ ។

Research and Promotion Khmer Laws Association